ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣១៧ សកបយ.

រាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការដោះស្រាយវិវាទការងាររួម

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

ប្រការ១.- ចំពោះការដោះស្រាយវិវាទការងាររួម បើក្នុងអនុសញ្ញារួមមិនបានគ្រោងនីតិវិធីសំរាប់ការដោះស្រាយទេ គ្រប់រឿងវិវាទត្រូវតែភាគីណាមួយប្តឹងទៅអធិការកិច្ចការងារ ។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអាគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក " ផ្លូវលេខ ១៨៤ " សង្កាត់ជ័យជំនះ ខ័ណ្ឌ

ភ្នំពេញ មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅរាជធានីភ្នំពេញ ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅខេត្ត-ក្រុងរៀងៗខ្លួន ។

ប្រការ២. ក្រោយពីបានទទួលបណ្តឹងរបស់ភាគីណាមួយ អធិការការងារត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ក្នុងរយៈពេល៤៨ ម៉ោង ។ បន្ទាប់មកអ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវពត៌មាន និងឯកសារជាភស្តុតាងនានា ដើម្បីផ្សះផ្សាវិវាទអោយបានសមស្រប ។

ការសាកសួរពត៌មានបន្ថែម ត្រូវធ្វើឡើងបួយភាគីម្តង១ ដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែមត្រូវធ្វើកំណត់ហេតុទុកជាឯកសារ ដោយមានចុះហត្ថលេខាអ្នកផ្សះផ្សា និងភាគីដែលផ្តល់ពត៌មាននោះផង ។

ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។

បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សាត្រូវរាយការណ៍ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

ប្រការ៣.. ក្នុងករណីដែលបានទទួលពត៌មានសព្វគ្រប់ពីភាគីទាំងអស់ហើយ អ្នកផ្សះផ្សាត្រូវធ្វើលិខិតអញ្ជើញម្តងទៀតអោយភាគីដែលពាក់ព័ន្ធទាំងអស់មកចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ។

ការផ្សះផ្សាត្រូវធ្វើក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ ការផ្សះផ្សានេះអាចធ្វើឡើងវិញបានតែតាមសំណូមពររួមនៃភាគីវិវាទ ។

ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។ បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

ប្រការ៤.. លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវផ្ញើជូនភាគីវិវាទតាមសំបុត្រអនុសិដ្ឋដែលមានហត្ថលេខាបញ្ជាក់ថាបានទទួលហើយ ឬលិខិតជូនផ្ទាល់ដៃដោយមានចុះហត្ថលេខាថាបានទទួល ។

ប្រការ៥.. ភាគីវិវាទអាចអោយគេជួយអម ឬអោយគេតំណាងខ្លួនបាន ។ ជនទាំងឡាយដែលអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបាន លុះត្រាតែជនទាំងនោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

ប្រការ៦.. ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់

ព្រមសះជានឹងគ្នា។ កំណត់ហេតុនោះត្រូវចុះទិដ្ឋាការដោយអ្នកផ្សះផ្សាព្រមទាំងហត្ថលេខារបស់ភាគីដែលពាក់ព័ន្ធ និងត្រូវចម្លងចែកភាគីទាំងអស់។

ប្រការ៧.- ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃ និងអនុភាពដូចគ្នា និងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលអោយគេតំណាងខ្លួន។ ប៉ុន្តែប្រសិនបើភាគីតំណាងកម្មករនិយោជិតពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀងនេះមិនជំទាស់ទាំងចំពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលអោយគេតំណាងខ្លួន។

ប្រការ៨.- ចំពោះវិវាទការងាររួមដែលភាគីពុំបានប្តឹង ឬអោយដំណឹងមកអធិការកិច្ចការងារទេនោះ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចចាត់ការផ្សះផ្សាតាមនីតិវិធីដែលកំណត់ក្នុងប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦ ខាងលើ ក្រោយពីបានដំណឹងពីវិវាទនេះភ្លាម។

ប្រការ៩.- វិវាទការងាររួមណាដែលមានការប៉ះពាល់ ឬអាចបណ្តាលអោយប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ អធិការកិច្ចការងារ ក្រោយពីបានទទួលដំណឹងស្តីពីវិវាទនេះ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងចាត់ការធ្វើការផ្សះផ្សាភ្លាម១ ចុះសាកសួរពតិមាន និងធ្វើការផ្សះផ្សាដល់ទីកន្លែងតែម្តង។

ប្រការ១០.- បើមានអនុសញ្ញាបានគ្រោងពីនីតិវិធីច្បាស់លាស់ សំរាប់ដោះស្រាយវិវាទការងាររួមហើយនោះ វិវាទការងាររួមត្រូវតែដោះស្រាយតាមនីតិវិធីនៃអនុសញ្ញានេះ។

ប្រការ១១.- ចំពោះវិវាទការងាររួមដែលផ្សះផ្សាមិនព្រមសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ជាបន្ទាន់ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីមានវិធានការដោះស្រាយបន្ត។

ប្រការ១២.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៦២ សកអ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ និង លេខ ១៤៤ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៣.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច